ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៥៤
ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩
សាលដីកា
លេខ: ៣៦ "VIII"
ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០

# សាលដីកា
# តាងនាមប្រជារាស្ត្រខ្មែរ
# តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធាន

២.លោក [redacted] ចៅក្រម (របាយការណ៍)

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោក [redacted] ចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

## តំណាងមហាអយ្យការ

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញារង

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ១២៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៤៩ ក្រII "រ" ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដែលមាន ៖

១.ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ហៅ ស្រួច ហៅ អ៊ួច ភេទប្រុស កើតឆ្នាំ១៩៨៨ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិមោង ឃុំគា ស្រុកមោងឫស្សី ខេត្តបាត់ដំបង មានទីលំនៅមុនពេលឃុំខ្លួន [redacted] ខេត្តបន្ទាយមានជ័យ ឪពុក



Scanned with CamScanner

ឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] ជានីតិជន ។ ឃុំខ្លួនតាមដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ១០៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ នៅពន្ធនាគារខេត្តបន្ទាយមានជ័យ។ (អ្នកប្ដឹងសាទុក្ខ)

មេធាវីការពារសិទ្ធិលោកស្រី [redacted] សុម៉ន

២.ជនជាប់ចោទឈ្មោះ [redacted] នៃរិទ្ធ ហៅ ម៉ាប់ ភេទប្រុស អាយុ ១៩ ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិស្វាយអី ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ទីលំនៅមុនពេលឃុំខ្លួន [redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ០១ នាក់ ជានីតិជន។ ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៤៧០ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៤ នៅពន្ធនាគារខេត្តបន្ទាយមានជ័យ។

៣.ជនជាប់ចោទឈ្មោះ [redacted] សុវឿត ហៅ ស្នា ភេទប្រុស អាយុ ២៥ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិស្ពៅលើ ឃុំមុខកំពូល ស្រុកមុខកំពូល ខេត្តកណ្ដាល មានទីលំនៅមុនពេលឃុំខ្លួនភូមិ [redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ០៣នាក់ ជានីតិជន ។ ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥៥៦ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៤ នៅពន្ធនាគារខេត្តបន្ទាយមានជ័យ។

<u>ជាប់ចោទពីបទ:</u> **ប៉ុនប៉ងឃាតកម្មគិតទុកជាមុន** ប្រព្រឹត្តនៅភូមិក្បាលស្ពាន ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ២៧ និងមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] រិទ្ធី ភេទប្រុស អាយុ ៥០ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted] ខេត្តបន្ទាយមានជ័យ។

**អំពីអង្គហេតុ៖**

កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៤ ម៉ោង ២០:៣០ នាទី មានការចោទប្រកាន់ថា មានករណីប៉ុនប៉ងឃាតកម្មគិតទុកជាមុនមួយកើតឡើងនៅចំណុចរ៉ាវថភ្លើងចាស់ ស្ថិតនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ បង្កឡើងដោយជនសង្ស័យមួយក្រុមមានគ្នា ០៤នាក់ ប្រដាប់ដោយដាវសាំម៉ូរ៉ៃ និងបំពង់ទីប ធ្វើសកម្មភាពកាប់ទៅលើជនរងគ្រោះឈ្មោះ [redacted] រតនា ភេទប្រុស អាយុ ១៩ ឆ្នាំ រស់នៅភូមិ [redacted] ខេត្តបន្ទាយមានជ័យ បណ្ដាលឱ្យរបួសផ្ទៃមុខ និងដៃជាទម្ងន់ ។ បន្ទាប់ពីធ្វើសកម្មភាពរួច ជនសង្ស័យគេចខ្លួនអស់ ។ ចំណែកជនរងគ្រោះត្រូវបានបញ្ជូនទៅមន្ទីរពេទ្យក្រុងបាងកក ប្រទេសថៃ ។ សមត្ថកិច្ចធ្វើការស្រាវជ្រាវរកមុខសញ្ញា និងឃាត់ខ្លួនជនសង្ស័យបានម្នាក់ឈ្មោះ [redacted] នរិទ្ធ ហៅ ម៉ាប់ ភេទប្រុស អាយុ ១៨ ឆ្នាំ ។ ចំណែកមុខសញ្ញាផ្សេងទៀតគឺឈ្មោះ [redacted] សុវឿត ហៅ ស្នា ឈ្មោះ គោប និងឈ្មោះ [redacted] ប៊ុនធឿន ហៅ ស្រួច ហៅ អ៊ួច ។



Scanned with CamScanner

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤១ (ផ) ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ផ្តន្ទាទោស៖

១.១.ឈ្មោះ [redacted] ធែរិទ្ធិ ហៅ ម៉ាប់ ភេទប្រុស អាយុ ១៩ ឆ្នាំ សញ្ជាតិខ្មែរ

១.២.ឈ្មោះ [redacted] សុវឿត ភេទប្រុស អាយុ ២៥ ឆ្នាំ សញ្ជាតិខ្មែរ

ដាក់ពន្ធនាគារម្នាក់ៗកំណត់ ២៨ (ម្ភៃប្រាំបី) ឆ្នាំ គិតពីថ្ងៃឃុំខ្លួនបណ្តោះអាសន្ន តាមបញ្ញត្តិមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌពីបទ ប៉ុនប៉ងឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិក្បាលស្ពាន ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៤ បទល្មើសមានចែងឱ្យផ្តន្ទាទោសបញ្ញត្តតាមមាត្រា ២៧ និងមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

១.៣.ឈ្មោះ [redacted] ប៊ុនធឿន ហៅ ស្រួច ហៅ អ៊ួច ភេទប្រុស កើតឆ្នាំ១៩៨៨ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៣០ (សាមសិប) ឆ្នាំ គិតពីថ្ងៃអនុវត្តទោស តាមបញ្ញត្តមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌ ពីបទ ប៉ុនប៉ុងឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិក្បាលស្ពាន ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៤ បទល្មើសមានចែងឱ្យផ្តន្ទាទោសបញ្ញត្តតាមមាត្រា ២៧ និងមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

២.ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ប៊ុនធឿន ហៅ ស្រួច ហៅ អ៊ួច ភេទប្រុស កើតឆ្នាំ១៩៨៨ ដើម្បីយកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ។

៣.បង្គាប់ឱ្យឈ្មោះ [redacted] ធែរិទ្ធិ ហៅ ម៉ាប់ ភេទប្រុសឈ្មោះ [redacted] សុវឿត ហៅ ស្នា ភេទប្រុស និងឈ្មោះ [redacted] ប៊ុនធឿន ហៅ ស្រួច ហៅ អ៊ួច ភេទប្រុស រួមគ្នាសងសំណងរដ្ឋប្បវេណីចំនួន ១០០ ០០០ ០០០ រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រិទ្ធី ភេទប្រុស។ ទាមទារលើសពីនេះបដិសេធចោល។

៤.សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធែរិទ្ធិ ហៅ ម៉ាប់ ភេទប្រុសឈ្មោះ [redacted] សុវឿត ហៅ ស្នា ភេទប្រុស កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ហៅ ស្រួច ហៅ អ៊ួច ភេទប្រុស និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមការកំណត់ច្បាប់។

-បានឃើញ បណ្តឹងទាស់លេខ ០៣ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] សាវឿត ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៤១ (ផ) ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចការផ្តន្ទាទោសពន្ធនាគារកំណត់ ២៨ឆ្នាំ។

. . . .



Scanned with CamScanner

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៩ (ច) ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១.ទទួលបណ្ដឹងទាស់របស់ឈ្មោះ [redacted] ប៊ុនធឿន ភេទប្រុស លើសាលក្រមលេខ ៤១ (ឆ) ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៦៨៨ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ធ្វើឡើងត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២.កែប្រែសេចក្ដីសម្រេចត្រង់ចំណុច ១.៣ សាលក្រមលេខ ៤១ (ឆ) ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៦៨៨ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៤ ដូចតទៅ៖

២.១.ពីផ្ដន្ទាទោសឈ្មោះ [redacted] ប៊ុនធឿន ភេទប្រុស កើតឆ្នាំ១៩៨៨ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៣០ (សាមសិប) ឆ្នាំ គិតពីថ្ងៃអនុវត្តទោស តាមបញ្ញត្តមាត្រា៩៥ នៃក្រមព្រហ្មទណ្ឌពីបទ ប៉ុនប៉ងឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៤ តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ មកជា៖ ដាក់ពន្ធនាគារកំណត់ ១៧ (ដប់ប្រាំពីរ) ឆ្នាំ គិតពីថ្ងៃអនុវត្តទោស តាមបញ្ញត្តិមាត្រា ៩៥ នៃក្រមព្រហ្មទណ្ឌពីបទ ប៉ុនប៉ងឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិក្បាលស្ពាន ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៤ តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

៣.សាលក្រមជំនុំជម្រះសាធាណរៈ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទ បើកផ្លូវប្ដឹងឧទ្ធរណ៍តាមការកំណត់ច្បាប់។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ២៤ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ១៩ (ច) ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០៣ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] សុវឿត ប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៤១ "ឆ" ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២៨ឆ្នាំ។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០២ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] ផៃរិទ្ធ ប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៤១ "ឆ" ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២៨ឆ្នាំ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៤៩ ក្រII "វ" ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

-១.ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] សុវឿត ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។



Scanned with CamScanner

២.ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦ របស់ជនជាប់ចោទឈ្មោះ [redacted] ឆៃរិទ្ធ ទុកជាត្រឹមត្រូវតាមច្បាប់។

៣.ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

៤.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៩ "ច" ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការ។

៥.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤១ "ឆ" ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការ លើកលែងតែ៖

ក.កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ឆៃរិទ្ធ ពីបទ ប៉ុនប៉ងឃាតកម្មគិតទុកជាមុន តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ មកជាបទប៉ុនប៉ងឃាតកម្ម តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌវិញ។

ខ.ចំណុចទី ១.១ នៃសាលក្រមព្រហ្មទណ្ឌលេខ ៤១ "ឆ" ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលផ្តន្ទាទោសឈ្មោះ [redacted] ឆៃរិទ្ធ ដាក់ពន្ធនាគារកំណត់២៨ (ម្ភៃប្រាំបី) ឆ្នាំ ត្រូវកែប្រែមកជា ដាក់ពន្ធនាគារកំណត់ ១២ (ដប់ពីរ) ឆ្នាំ វិញ ពីបទ ប៉ុនប៉ងឃាតកម្ម ប្រព្រឹត្តនៅភូមិស្ពាន ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០១៤ បទល្មើសប្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

គ.បដិសេធចំណុចទី ១.២ នៃសាលក្រមព្រហ្មទណ្ឌលេខ ៤១ "ឆ" ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលផ្តន្ទាទោសលើឈ្មោះ [redacted] សុវឿត ចោលជាអសារបង់។

ឃ.ឱ្យឈ្មោះ [redacted] សុវឿត បានរួចខ្លួនពីបទ ប៉ុនប៉ងឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិស្ពាន ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ។

ង.បង្គាប់មកស្ថាប័នមានសមត្ថកិច្ច ធ្វើការដោះលែងឈ្មោះ [redacted] សុវឿត ចេញពីពន្ធនាគារជាបន្ទាន់ បើឈ្មោះនេះមិនត្រូវបានឃុំខ្លួនពីបទល្មើសអ្វីផ្សេងទៀតទេ។

-ចំណុចផ្សេងពីនេះ រក្សាទុកដដែល។

៦.បន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ឆៃរិទ្ធ និងឈ្មោះ [redacted] ប៊ុនធឿន តាមច្បាប់។



Scanned with CamScanner

៧.សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩។

-ទុកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងសាទុក្ខលេខ ១២៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៤៩ ក្រII "វ" ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ប្តឹងសាទុក្ខមកនេះ ហើយលើកក្នុងសារណារបស់ខ្លួនថា មិនបានប្រព្រឹត្តដូចការចោទប្រកាន់ និងផ្តន្ទាទោសដូចតុលាការអង្គសេចក្តីសម្រេចឡើយ។ ផ្អែកតាមការយល់ឃើញរបស់ តុលាការអង្គសេចក្តី ឃើញថាជនជាប់ចោទបានឆ្លើយសារភាពនៅមន្ត្រីនគរបាលយុត្តិធម៌ ដែលមានលក្ខណៈស៊ីសង្វាក់និងអង្គហេតុហើយ។ ដូច្នេះ ការដោះសារមិនមានសំអាងហេតុដូចក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ។ តំណាងមហាអយ្យការឯកភាពក្នុងការយល់ឃើញ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍។

ហេតុដូច្នេះ តំណាងមហាអយ្យការប្តឹងសុំចំពោះតុលាការកំពូលឱ្យ៖

១.ទទួលបណ្តឹងសាទុក្ខលេខ ១២៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ទុកជាត្រឹមត្រូវតាមតម្រង់ច្បាប់ តែបដិសេធ ដោយខុសនឹងគតិច្បាប់។

២.តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤៩ ក្រII "វ" ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន បានឆ្លើយថា នៅពេលកើតហេតុ ខ្លួនបានទៅមើលគេស្រាប់តែត្រូវគេចាប់ខ្លួនតែម្តង ខ្ញុំពុំបានដឹងរឿងអ្វីទេ ។

ខ្លួនសំណូមពរ សុំឱ្យតុលាការកំពូលមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

-លោកស្រី [redacted] សុវិន មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន បានធ្វើសេចក្តីសន្និដ្ឋានថា៖ នៅក្នុងអង្គហេតុ និងអង្គច្បាប់ ឃើញថា តាមសាច់រឿង និងតាមសាក្សីនៅមានវិមតិសង្ស័យនៅឡើយទេ តុលាការបានផ្តន្ទាទោសលើកូនក្តីខ្លួនចំនួន ១៧ឆ្នាំ យោងតាមអង្គហេតុ នៅក្នុងកំណត់ហេតុសួរចម្លើយគ្មានភាពស៊ីសង្វាក់គ្នា ទៅនឹងការចោទប្រកាន់មកលើកូនក្តីខ្លួននៅឡើយទេ ចំណែកឯចម្លើយសាក្សីបានបញ្ជាក់ផងដែរថា មានមនុស្សបិទមុខ ៤នាក់ មកកាប់ទៅលើជនរងគ្រោះ តែមិនបានដឹងថាជាអ្នកណាពិតប្រាកដទេ ។



Scanned with CamScanner

សំណូមពរ: សូមតុលាការមេត្តាជួយ បន្ធូរបន្ថយទោសឱ្យកូនក្ដីខ្ញុំផង ។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីឱ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

១-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ១២៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៦៥ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបាន។

២-យល់ឃើញថា តុលាការកំពូលបានធ្វើការជូនដំណឹងដល់ជនជាប់ចោទ ដែលជាម្ចាស់បណ្ដឹងសាទុក្ខឈ្មោះ [redacted] ប៊ុនធឿន អំពីការចុះបញ្ជីសំណុំរឿង និងបង្គាប់ឱ្យឈ្មោះនេះ ដាក់សារណាការពារជូនមកតុលាការកំពូល តាមលិខិតចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ស្របតាមមាត្រា ៤២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌហើយ ប៉ុន្តែម្ចាស់បណ្ដឹងសាទុក្ខពុំបានដាក់សារណាការពារជូនតុលាការកំពូលតាមការបង្គាប់នេះទេ។

៣-យល់ឃើញថា តាមមាត្រា ៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា តុលាការកំពូលត្រូវសម្រេចលើបញ្ហាច្បាប់ ដែលលើកឡើងដោយអ្នកប្ដឹងសាទុក្ខ និងដែលមានរៀបរាប់ក្នុងសារណា។ សំណុំរឿងក្ដីនេះជនជាប់ចោទ ពុំបានដាក់សារណាការពារជូនមកតុលាការកំពូលទេ ក៏ប៉ុន្តែជនជាប់ចោទបានចូលឆ្លើយនៅចំពោះមុខសវនាការតុលាការកំពូល ហើយមេធាវីបានធ្វើសេចក្ដីសន្និដ្ឋាន ។ ដូច្នេះតុលាការកំពូលធ្វើការពិចារណាលើចម្លើយ និងសេចក្ដីសន្និដ្ឋាននេះ។

៤-យល់ឃើញថា តាមចម្លើយរបស់ជនជាប់ចោទថា ខ្លួនសំណូមពរសុំឱ្យតុលាការកំពូល ធ្វើការបន្ថយទោសដល់រូបខ្លួន។ តុលាការកំពូលពិនិត្យឃើញថា សំណុំពរនេះត្រូវបានសាលាឧទ្ធរណ៍ពិចារណារួចហើយ ដូចមានក្នុងសំអាងហេតុចំណុចទី ១២ នៃសាលដីកា។ តុលាការកំពូលឯកភាពលើសំអាងហេតុនេះ ដោយពុំចាំបាច់សរសេរបញ្ជាក់ជាថ្មីឡើងវិញទេ។

៥-យល់ឃើញថា មេធាវីការពារក្ដីឱ្យជនជាប់ចោទ បានសន្និដ្ឋានថា សាក្សីឈ្មោះ [redacted] មឿត ហៅ ម៉ន, [redacted] នាំ ហៅ រ៉ា, [redacted] រ៉ាដូ ហៅ ដូ បានបញ្ជាក់ត្រឹមតែមនុស្សបិទមុខ ៤ នាក់ មកកាប់លើជនរងគ្រោះទេ។ តុលាការកំពូលពិនិត្យឃើញថា ការលើកឡើងនេះពុំត្រឹមត្រូវទេ ពីព្រោះក្នុងសំអាង



Scanned with CamScanner

ហេតុចំណុចទី ៨ នៃសំអាងហេតុរបស់សាលាឧទ្ធរណ៍ បានបញ្ជាក់ច្បាស់អំពីធាតុផ្សំនៃបទល្មើសលើឈ្មោះ [redacted] ប៊ុនធឿន ដែលបញ្ជាក់ ដោយឈ្មោះ [redacted] ផៃរិទ្ធ ។

៦-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៤៩ ក្រII "វ" ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមគតិច្បាប់ហើយ។

## ហេតុដូច្នេះសម្រេច

១-បដិសេធបណ្តឹងសាទុក្ខលេខ ១២៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤៩ ក្រII "វ" ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩របស់សាលាឧទ្ធរណ៍ ទុកជាបានការ។

៣-សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០។

Scanned with CamScanner